**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបិទ
# សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៥

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងសន្និបាតនាពេលនេះ!**

បន្ទាប់ពីបានស្តាប់បទបង្ហាញអំពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ជាពិសេសបទពិសោធន៍ល្អៗដែលទទួលបានពីការអនុវត្តរបស់សមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅទូទាំងប្រទេសក្នុងអង្គសន្និបាតនាពេលនេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវការអបអរសាទរ និងការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតចំពោះសមាជិក សមាជិកានៃអង្គសន្និបាតទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការងារប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ហើយបាននាំមកនូវជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា**

លទ្ធផលដែលទទួលបានជាផ្លែផ្កាទាំងនេះ បានមកដោយសារមានក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រត្រឹមត្រូវ និងមានក្របខណ្ឌគតិយុត្ត រួមជាមួយក្របខណ្ឌស្ថាប័ន ដែលបង្កើតបាននូវបរិយាកាសគាំទ្រដល់ការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍សម្រាប់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល បណ្តាញប្រជាជនគន្លឹះ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍។ ការដឹកនាំការបង្ការដល់ក្រុមប្រជាជនគន្លឹះ ផ្តល់នូវសេវាថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងធ្វើការក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូពាក់ព័ន្ធ និងអង្គការអន្តរជាតិដើម្បីពង្រឹងសហគមន៍តែមួយ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍(community-led responses) ដោយឈរលើគោលការណ៍ "**មិនទុកនរណាម្នាក់ចោលដោយមិនបានទទួលការយកចិត្តទុកដាក់**" និងផ្អែកលើគោលការណ៍គ្រឹះ ក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិ និងសហគមន៍ និងភាពជាម្ចាស់ អនុលោមទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលនយោបាយជាតិ ហិរញ្ញប្បទាន

ប្រកបដោយចីរភាព កិច្ចសហប្រតិបត្តិការជាពហុវិស័យ អន្តរាគមន៍ផ្អែកលើភស្តុតាង គណនេយ្យភាព និងតម្លាភាព។

កម្ពុជាបានប្តេជ្ញាចិត្តក្នុងការបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈ ស្រប នឹងគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយធានាការរស់នៅប្រកបដោយសុខភាព ល្អ និងបង្កើនសុខុមាលភាពសម្រាប់ទាំងអស់គ្នា និងសម្រេចបានអត្រាគ្របដណ្តប់សុខភាពជាសកល ដោយរួមបញ្ចូលការការពារហានិភ័យហិរញ្ញវត្ថុ ក្នុងការទទួលបានសេវាថែទាំសុខភាពសំខាន់ៗប្រកប ដោយគុណភាព។ ជារួម ការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានការថយចុះ ប៉ុន្តែមានការកើន ឡើងក្នុងចំណោមបុរស។ ការឆ្លងថ្មីក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស ក្រុមបុរសរកស៊ីផ្លូវភេទ ក្រុមស្ត្រីបំប្លែងភេទ ជាពិសេសក្នុងចំណោមយុវវ័យកំពុងមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ បន្ថែមលើ នេះ ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក៏នៅមានអត្រាខ្ពស់នៅឡើយផងដែរ។

ទោះជាយ៉ាងណា ពិភពលោកក៏បានបោះជំហានទៅមុខគួរឱ្យកត់សម្គាល់ គឺកន្លែងណាដែល បានអនុវត្ត និងពង្រីកការបង្ការបានល្អ កន្លែងនោះទទួលបានប្រសិទ្ធភាពខ្ពស់។ អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍កាន់តែច្រើនឡើងបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឯការ រើសអើងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍កាន់តែឈានទៅលុបបំបាត់ទាំងស្រុង។ ហេតុនេះ ការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០៣០ គឺជាផ្នែកមួយដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបានអនុម័តដោយប្រទេសសមាជិកអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៥។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា

ដើម្បីជំរុញការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅឆ្នាំបន្ទាប់ឱ្យកាន់តែ មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពបន្ថែមទៀត ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១- ធានាឱ្យបាននូវចីរភាព និងភាពជន់នៃការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ គ្រប់ លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសក្នុងឃុំ សង្កាត់ ទាំងអស់នៅទូទាំង ប្រទេស និងធ្វើការបញ្ជ្រាប និងបញ្ចូលសកម្មភាពឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ទៅ ក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។

២- ពង្រឹង និងពង្រីកសេវាបង្ការ ធ្វើតេស្ត និងថែទាំព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍រួមគ្នា ជាពិសេសក្រុមប្រឈម និងក្រុមយុវវ័យនៅតាមសហគមន៍ ដោយអនុវត្តការប្រើប្រាស់ស្រោម អនាម័យ១០០% វិធីប្រើប្រាស់ឱសថបង្ការជាមុននៅពេលមានការប្រព្រឹត្តប្រឈមនឹងការឆ្លង មេរោគអេដស៍(PrEP) វិធីប្រើប្រាស់ឱសថបង្ការក្រោយពេលមានការប្រព្រឹត្តប្រឈមនឹងការ ឆ្លងមេរោគអេដស៍(PEP) និងការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង រួមនឹងការប្រើប្រាស់ ឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ។

៣- រក្សាស្រោមអនាម័យឱ្យមាននៅគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ដែលត្រូវការប្រើប្រាស់ប្រកប ដោយគុណភាពខ្ពស់ និងបន្តលើកទឹកចិត្តដល់ក្រុមយុវវ័យដែលរួមភេទដូចគ្នាឱ្យទៅធ្វើតេស្តរក

មេរោគអេដស៍ និងប្រើប្រាស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍តាមរយៈការប្រើស្រោមអនាម័យ ១០០% នៅរាល់ពេលរួមភេទជាមួយដៃគូផ្សេង។

៤- ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គមសម្រាប់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ និងបង្កើតបរិយាកាសអំណោយផលដល់ការទទួលបាននូវសេវាព្យាបាល និងថែទាំជំងឺអេដស៍ សេវាគាំទ្រសុខាភិបាលនានា ព្រមទាំងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាពសម្រាប់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍។

៥- សូមអំពាវនាវឱ្យមានការចូលរួមយ៉ាងសកម្ម និងគាំទ្រខ្លាំងក្លាដល់បុគ្គលិកសុខាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ក្រុមប្រជាជនគន្លឹះ ដើម្បីធ្វើការជាមួយគ្នាដោយជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក សំដៅឆ្ពោះទៅការបិទបញ្ចប់អេដស៍នាពេលខាងមុខ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា អនុសាសន៍ទាំងអស់ខាងលើនេះ នឹងក្លាយជាកម្លាំងចលករក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ និងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី ៦ ឆ្នាំ២០២៤-២០២៨ ឱ្យទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់សូមទទួលបាននូវសុខភាពល្អ និងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀតនាឆ្នាំថ្មីខាងមុខនេះ និងសូមប្រកាសបិទ “**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ ២០២៥**” ចាប់ពីពេលនេះតទៅ។

សូមអរគុណ។